# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ១៤/២១ ក.ធ.ស.ល.ក.ន

ថ្ងៃ អង្គារ ៦ កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០២១

## សេចក្តីណែនាំ
## ស្តីពី
## ការបន្លឺសម្លេងស្គរ ជួងគងរំពង នៅវេលាម៉ោង ៦:០០នាទីល្ងាច ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១

**យោង ៖** លិខិតលេខ: ១០៧/២១ ស.ណ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ក្រសួងធម្មការ និងសាសនា មានកិត្តិយសសូមថ្វាយ ប្រគេន និងជូនដំណឹងដល់ **សម្តេចព្រះសង្ឃនាយកទាំងពីរគណៈ** ថ្នាក់ដឹកនាំគ្រប់សាសនា និងលោកប្រធានមន្ទីរធម្មការ និងសាសនារាជធានី-ខេត្ត ព្រះមេត្តា-មេត្តា ជ្រាបថា ជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ២០១៧ មក គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ.) តែងបានសហការជាមួយក្រសួងធម្មការ និងសាសនា មេដឹកនាំសាសនាធំៗ ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំកម្មវិធីអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ក្នុងគោលបំណងបួងសួងឱ្យប្រជាជនកម្ពុជា ក៏ដូចជាប្រជាជនលើពិភពលោកទទួលបានសេចក្តីសុខ ជៀសផុតពីការបោកប្រាស និងអំពើជួញដូរមនុស្ស ដែលជាទាសភាពសម័យទំនើប។

កម្មវិធីអន្តរសាសនាប្រឆាំងការជួញដូរមនុស្សឆ្នាំ២០២១នេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នឹងផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត អានសុន្ទរកថាបើកកម្មវិធី ក្រោមប្រធានបទ "*សូមពិភពលោក រួចផុតពីជំងឺកូវីដ-១៩ និងអំពើជួញដូរមនុស្ស*" (ដែលនឹងថតវីដេអូដោយស្ថានីយទូរទស្សន៍) មុននឹងភ្ជាប់រូបភាពបួងសួងតាមសាសនានីមួយៗ ហើយនឹងត្រូវចាក់ផ្សាយព្រមៗគ្នា គ្រប់ប៉ុស្តិ៍ទូរទស្សន៍ផ្ទៃ និងឯកជននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បណ្តាញព័ត៌មាន និងបណ្តាញសង្គម។

ដើម្បីញ៉ាំងកម្មវិធីនេះ បានផ្សព្វផ្សាយដល់គ្រប់ស្រទាប់មហាជនទាំងក្នុងប្រទេស និងក្រៅប្រទេស ក្រសួងធម្មការ និងសាសនា សូមធ្វើការណែនាំដូចខាងក្រោម៖

-គ្រប់វត្តអារាម និងព្រះវិហារនៃគ្រប់សាសនា ត្រូវបន្លឺសម្លេងស្គរ ជួងគងរំពង នៅវេលាម៉ោង ៦:០០នាទីល្ងាច ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១។

-គ្រប់វត្តអារាម និងព្រះវិហារនៃគ្រប់សាសនា ត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល ជាពិសេសត្រូវប្រកាន់ខ្ជាប់ជានិច្ចនូវវិធានការ "៣កុំ ៣ការពារ" របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ទទួលបានសេចក្តីណែនាំនេះ **សូមសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ** ថ្នាក់ដឹកនាំនៃគ្រប់សាសនា និងលោកប្រធានមន្ទីរធម្មការ និងសាសនារាជធានី-ខេត្ត ព្រះមេត្តា-មេត្តា សហការអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**រដ្ឋមន្ត្រី**

ឈិត_សុខុន

**ចម្លងថ្វាយ ប្រគេន-ជូន:**
-សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ក្រសួងសុខាភិបាល
-គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
**-ដើម្បីថ្វាយ ប្រគេន-ជូនជ្រាប-**
-ប្រធានមន្ទីរធម្មការ និងសាសនារាជធានី-ខេត្ត
-គ្រប់មេដឹកនាំសាសនា
**-ដើម្បីសហការអនុវត្ត-**
-ឯកសារ-កាលប្បវត្តិ

# 393, តិវិថី ព្រះស៊ីសុវត្ថិ សង្កាត់ វត្តភ្នំ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៦៥៥ ទូរសារ : (៨៥៥-២៣) ៧២៥ ៦៥៥ អ៊ីម៉ែល : ministry religion@yahoo.com Web site : www.mocar.gov.kh